វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺះ

- អតិផរណាប្រទេសកម្ពុជា មានកម្រិតទាបត្រឹម ២,២% ក្នុងខែកក្កដា
- ប្រទេសឥណ្ឌូនេស៊ីប្រកាសអតិរេកពាណិជ្ជកម្ម សម្រាប់ខែសីហា
- តម្លៃប្រេងធ្លាក់ចុះ ស្របពេលដែលអារ៉ាប៊ីសាអូឌីតចាប់ផ្តើមការផ្គត់ផ្គង់ឡើងវិញ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះអោយមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### អតិផរណាប្រទេសកម្ពុជា មានចំនួន ២,២ % ក្នុងខែ កក្កដា

យោងតាម របាយការណ៍អតិផរណាចុងក្រោយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា តម្លៃទំនិញ និងសេវាកម្មនៅក្នុងរាជធានីភ្នំពេញបានកើនឡើង២,២% ក្នុងខែកក្កដា ដោយផ្អែកមូលដ្ឋានប្រចាំឆ្នាំ។ ការកើនឡើងនេះគឺដោយសារតែកំណើននៃអាហារ និងភេសជ្ជៈគ្មានជាតិអាល់កុល(២,២%) ភេសជ្ជៈមានជាតិអាល់កុល ថ្នាំដែលមានសារជាតិណាកូទិច និងថ្នាំជក់(៦,៣%) និងការបរិភោគអាហារនៅតាមភោជនីយដ្ឋាន (៦,១%) ។

### តារាងប្រចាំសប្តាហ៍៖ ការចំណាយតាមវិស័យមានកំណើនយឺតនៅក្នុងឆមាសទី១ នៃឆ្នាំ២០១៩

តារាងប្រចាំសប្តាហ៍នេះ បង្ហាញពីចំណាយចរន្តក្នុងឆមាសទី១ គិតពីឆ្នាំ២០១៥-២០១៩ ទៅលើវិស័យចំនួន០៥ រួមមានៈ រដ្ឋបាលទូទៅ ការពារជាតិ និងសន្តិសុខ វិស័យសង្គមកិច្ច វិស័យសេដ្ឋកិច្ច និងចំណាយផ្សេងៗ។

តួលេខបានបង្ហាញថា ការចំណាយសរុបសម្រាប់ឆ្នាំ ២០១៩ មានកំណើនយឺតគួរឱ្យកត់សម្គាល់បើធៀបទៅនឹងប៉ុន្មានឆ្នាំចុងក្រោយនេះ ពី២៩%ជាមធ្យម មកត្រឹម៨% ។ ការចំណាយលើរដ្ឋបាលទូទៅជាចំណាយបាននាំមុខគេ និងជាប្រភេទចំណាយខ្ពស់បំផុត បន្ទាប់មកគឺចំណាយទៅលើវិស័យការពារជាតិ និងសន្តិសុខ។

គំនូសតាងសប្តាហ៍៖ ការចំណាយចរន្តនៅឆមាសទី១ ឆ្នាំ ២០១៩




ប្រភព៖ ច្បាប់ទូទាត់ថវិកាពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រទេសឥណ្ឌូនេស៊ីប្រកាសអតិរេកពាណិជ្ជកម្ម សម្រាប់ខែសីហា

ប្រទេសឥណ្ឌូនេស៊ីបានប្រកាសអតិរេកពាណិជ្ជកម្មដែលមានតម្លៃស្មើនឹង០,០៩ប៊ីលានដុល្លារសម្រាប់ខែសីហា នេះបើធៀបនឹងឱនភាពថវិកាចំនួន០,៩៥ ប៊ីលានដុល្លារ សម្រាប់ខែដូចគ្នាក្នុងឆ្នាំ២០១៨, យោងតាមស្ថិតិថ្មី ចេញផ្សាយដោយ ក្រសួងពាណិជ្ជកម្ម។ ក្នុងរយៈពេល៨ខែដំបូងនៃឆ្នាំ២០១៩នេះ ឱនភាពពាណិជ្ជកម្ម បានបន្ថយនៅត្រឹម ១,៨១ ប៊ីលានដុល្លារ ពី ៤,៨១ ប៊ីលានដុល្លារ ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

ទោះយ៉ាងណាក៏ដោយ អតិរេកនេះបានធ្លាក់ចុះទាបជាងការរំពឹងទុករបស់ទីផ្សារ ដែលស្មើនឹង០,១៩ប៊ីលានដុល្លារ ដោយសារតែការនាំចេញបានធ្លាក់ចុះ១០% បើធៀបនឹងការធ្លាក់ចុះដែលបានរំពឹងទុកត្រឹមតែ៦%។ ការធ្លាក់ចុះនេះគឺបណ្តាលមកពីការបន្តធ្លាក់ចុះនៃការនាំចេញប្រេង និងឧស្ម័នដែលស្មើនឹង ៣៩,៥ %។

## សេដ្ឋកិច្ចពិភពលោក

### តម្លៃប្រេងធ្លាក់ចុះ ស្របពេលដែលអារ៉ាប៊ីសាអូឌីតចាប់ផ្តើមការផ្គត់ផ្គង់ឡើងវិញ

ព្រះអង្គម្ចាស់ Abdulaziz bin Salman រដ្ឋមន្ត្រីក្រសួងថាមពលរបស់អារ៉ាប៊ីសាអ៊ូឌីតបានប្រកាសធានាដល់ទីផ្សារ ថា ក្រុមហ៊ុនផ្គត់ផ្គង់ប្រេងបានស្តារផលិតកម្មឡើងវិញ និងត្រលប់ទៅរកស្ថានភាពដែលធ្លាប់ផលិតបាន មុនការវាយប្រហារទៅលើទីតាំងប្រេង។ ការប្រកាសនេះបានធ្វើឱ្យតម្លៃប្រេងធ្លាក់ចុះ៦% បន្ទាប់ពីកើនឡើងប្រមាណ១៥% កាលពីដើមសប្តាហ៍កន្លងទៅ។

នាយកប្រតិបត្តិទីភ្នាក់ងារថាមពលអន្តរជាតិ លោក Fatih Birol បានធ្វើការបញ្ជាក់នៅក្នុង សេចក្តីថ្លែងការណ៍ បន្ថែមដើម្បី អោយស្ថានភាពកាន់តែមានភាពជឿជាក់ថា ទីផ្សារប្រេងពិភពលោកនាពេលនេះត្រូវបានផ្គត់ផ្គង់យ៉ាងល្អជាមួយនឹងស្តុកប្រេងពាណិជ្ជកម្មគ្រប់គ្រាន់ ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យ និងព័ត៌មានសេដ្ឋកិច្ចក្នុងសប្តាហ៍ខាងមុខនេះ រួម មាន ៖ ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ហ្វីលីពីន និង ថៃ។

ខាងក្រោម គឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍដែលក្រុមFACTនឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី២៣ ខែ កញ្ញា ២០១៩

- អត្រាអតិផរណាគោលរបស់សឹង្ហបុរី ខែសីហា
- តុល្យភាពថវិកាហ្វីលីពីន ខែសីហា
- ផលិតកម្មឧស្សាហកម្មតៃវ៉ាន់ ខែសីហា
- គណនីចរន្តរបស់ហុងកុង ត្រីមាសទី២ ឆ្នាំ២០១៩

ថ្ងៃអង្គារ ទី២៤ ខែកញ្ញា ២០១៩

- ផលិតផលឧស្សាហកម្មថៃ ខែសីហា
- សន្ទស្សន៍សេដ្ឋកិច្ចនាំមុខជប៉ុន ខែកក្កដា
- ការផ្គត់ផ្គង់ប្រាក់M2 របស់តៃវ៉ាន់ ខែសីហា

ថ្ងៃពុធ ទី២៥ ខែកញ្ញា ២០១៩

- កំណត់ហេតុកិច្ចប្រជុំគោលនយោបាយរូបិយវត្ថុរបស់ធនាគារជប៉ុន
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ថៃ
- អត្រាអតិផរណារបស់ម៉ាឡេស៊ី ខែសីហា
- សន្ទស្សន៍ថៃដន្យរបស់ម៉ាឡេស៊ី ខែកក្កដា

ថ្ងៃព្រហស្បតិ៍ ទី២៦ ខែកញ្ញា ២០១៩

- សន្ទស្សន៍ភាពជឿជាក់របស់អតិថិជននៅកូរ៉េខាងត្បូង ខែកញ្ញា
- ការសម្រេចចិត្តអត្រាការប្រាក់របស់ហ្វីលីពីន
- តុល្យភាពពាណិជ្ជកម្មនៅហុងកុង ខែសីហា

ថ្ងៃសុក្រ ទី២៧ ខែកញ្ញា ២០១៩

- ការវិនិយោគសញ្ញាប័ណ្ណបរទេសនៅជប៉ុន ថ្ងៃទី២១ ខែកញ្ញា
- តម្លៃនាំចេញសឹង្ហបុរី ខែសីហា
- ប្រាក់ចំណេញឧស្សាហកម្មចិន ខែសីហា
- ការវិនិយោគភាគហ៊ុន ដោយជនបរទេសនៅជប៉ុន ថ្ងៃទី២១ ខែកញ្ញា